ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.3.5.....សហវ.ប្រយត

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦

ប្រកាសអន្តរក្រសួង
ស្តីពី
ការកំណត់ថ្លៃឈ្នួលដីតំបន់អាជ្ញាបណ្ណធនធានព្រៃ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងព្រៃ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព្រៃ និងថាមពល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៣៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៨៩១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រគល់សិទ្ធិជូនប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត និងប្រធានរតនាគាររាជធានី ខេត្ត
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល

សម្រេច

ប្រការ ១.~

សម្បទានិកដែលទទួលអាជ្ញាបណ្ណធនធានរ៉ែទាំងអស់ លើកលែងតែអាជ្ញាបណ្ណកែច្នៃធនធានរ៉ែ ត្រូវបង់ជូនរដ្ឋ នូវថ្លៃឈ្នួលដីតំបន់អាជ្ញាបណ្ណធនធានរ៉ែ (ហៅកាត់ថាថ្លៃឈ្នួលដី) ស្របតាមការកំណត់ក្នុងប្រកាសអន្តរក្រសួងនេះ។

ប្រការ ២.~

ថ្លៃឈ្នួលដីត្រូវកំណត់ដូចខាងក្រោម÷

លរ	ប្រភេទអាជ្ញាបណ្ណធនធានរ៉ែ	ថ្លៃឈ្នួលដីប្រចាំឆ្នាំ
១	អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ	
	-សម្រាប់អាជីវកម្មជីកដីចល័ត	៥(ប្រាំ) ដុល្លារអាមេរិក/ភូមិ
	-សម្រាប់រ៉ែខ្សាច់ ក្រួស ឡាតេរីត ដីឥដ្ឋ អាចម៍ដី	១៥(ដប់ប្រាំ) ដុល្លារអាមេរិក/ហិកតា
	-សម្រាប់រ៉ែមាស	៥០(ហាសិប) ដុល្លារអាមេរិក/ហិកតា
	-សម្រាប់រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ	៥០(ហាសិប) ដុល្លារអាមេរិក/ហិកតា
២	អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម	
	-សម្រាប់ថ្មកំបោរ ធ្យូងថ្ម ធ្យូងភក់	២០(ម្ភៃ) ដុល្លារអាមេរិក/ហិកតា
	-សម្រាប់រ៉ែខ្សាច់ ក្រួស ឡាតេរីត ដីឥដ្ឋ អាចម៍ដី	៣០(សាមសិប) ដុល្លារអាមេរិក/ហិកតា

	-សម្រាប់ថ្មសំណង់ ថ្មអារ ថ្មម៉ាប ថ្មក្រានីត ថ្មកែវ ថ្មភក់	៥០(ហាសិប) ដុល្លារអាមេរិក/ហិកតា
៣	អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ	
	-សម្រាប់រ៉ែត្បូងថ្មមានតម្លៃ-ពាក់កណ្តាលមានតម្លៃ	៥០(ហាសិប) ដុល្លារអាមេរិក/ហិកតា
	-សម្រាប់ថ្មសម្ពាង	៥០(ហាសិប) ដុល្លារអាមេរិក/ហិកតា
៤	អាជ្ញាបណ្ណស្វែងរុករក	
	-ពីឆ្នាំទី១ ដល់ទី៣	០.២០(ម្ភៃសេន) ដុល្លារអាមេរិក/ហិកតា
	-ពីឆ្នាំទី៤ ដល់ទី៥	០.៣០(សាមសិបសេន) ដុល្លារអាមេរិក/ហិកតា
	-ពីឆ្នាំទី៦ ដល់ទី៧	០.៥០(ហាសិបសេន) ដុល្លារអាមេរិក/ហិកតា
	-ពីឆ្នាំទី៨ ឡើងទៅ	១(មួយ) ដុល្លារអាមេរិក/ហិកតា
៥	អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ	
	-ពីឆ្នាំទី១ ដល់ទី៥	៧(ប្រាំពីរ) ដុល្លារអាមេរិក/ហិកតា
	-ពីឆ្នាំទី៦ ដល់ទី១០	១០(ដប់) ដុល្លារអាមេរិក/ហិកតា
	-ពីឆ្នាំទី១១ ដល់ទី២១	១៥(ដប់ប្រាំ) ដុល្លារអាមេរិក/ហិកតា
	-ពីឆ្នាំទី២២ ឡើងទៅ	២០(ម្ភៃ) ដុល្លារអាមេរិក/ហិកតា

ប្រការ ៣.~

សម្បទានិកត្រូវបង់ថ្លៃឈ្នួលដី ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃសុពលភាពអាជ្ញាបណ្ណធនធានរ៉ែ។

ថ្លៃឈ្នួលដី ត្រូវបង់សរុបតែមួយលើក ទៅតាមអាយុកាលរបស់អាជ្ញាបណ្ណធនធានរ៉ែ លើកលែងតែអាជ្ញាបណ្ណស្វែងរុករក និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ដែលត្រូវអនុវត្តស្របតាមប្រការ៤ នៃប្រកាសអន្តរក្រសួងនេះ។

ប្រការ ៤.~

ការបង់ថ្លៃឈ្នួលដីសម្រាប់អាជ្ញាបណ្ណស្វែងរុករក ត្រូវអនុវត្តដូចខាងក្រោម÷

- នៅពេលទទួលបានអាជ្ញាបណ្ណស្វែងរុករកដំបូង សម្បទានិកត្រូវបង់ថ្លៃឈ្នួលដីសរុបតែមួយលើកទៅតាមអាយុកាលរបស់អាជ្ញាបណ្ណ។
- នៅពេលទទួលបានការពន្យារបន្តអាជ្ញាបណ្ណស្វែងរុករកលើកទីមួយ ឬលើកជាបន្តបន្ទាប់ទៀតនោះ សម្បទានិកត្រូវបង់ថ្លៃឈ្នួលដីសរុប ទៅតាមអាយុកាលរបស់អាជ្ញាបណ្ណ។ ប្រសិនបើមានការប្រគល់ផ្ទៃក្រឡាសងវិញ នៅឆ្នាំទីមួយ ឬឆ្នាំទីពីរ នៃរយៈពេលសុពលភាពអាជ្ញាបណ្ណលើកដំបូង ឬក្នុង

ឆ្នាំទីមួយ នៃរយៈពេលសុពលភាពអាជ្ញាបណ្ណពន្យារបន្ត សម្បទានិកត្រូវបានទទួលការកាត់កងថ្លៃឈ្នួលដី សមាមាត្រទៅនឹងទំហំផ្ទៃក្រឡាដែលបានប្រគល់សងវិញ។

ការបង់ថ្លៃឈ្នួលដីសម្រាប់អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ត្រូវអនុវត្តដូចខាងក្រោម÷

- សម្បទានិកត្រូវបង់ថ្លៃឈ្នួលដីប្រចាំឆ្នាំទៅតាមឆ្នាំសារពើពន្ធ។
- ថ្លៃឈ្នួលដីឆ្នាំដំបូង និងឆ្នាំបញ្ចប់សុពលភាពនៃអាជ្ញាបណ្ណ ត្រូវគណនាតាមសមាមាត្រជាក់ស្តែងនៃចំនួនខែក្នុងឆ្នាំនីមួយៗ។
- ថ្លៃឈ្នួលដីចាប់ពីឆ្នាំទីពីរទៅ សម្បទានិកត្រូវបង់ឱ្យបានមុនថ្ងៃទី១៥ ខែមករា ជារៀងរាល់ឆ្នាំ។

ប្រការ ៥.~

រជ្ជទេយ្យការចំណូលរបស់ក្រសួងរ៉ែនិងថាមពល និងរជ្ជទេយ្យការចំណូលរបស់មន្ទីររ៉ែនិងថាមពល រាជធានី ខេត្ត ត្រូវបើកគណនីរជ្ជទេយ្យការចំណូល នៅតាមធនាគារដែគ្ន តាមការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សម្រាប់ថ្នាក់កណ្តាល សម្បទានិកត្រូវបង់ថ្លៃឈ្នួលដីចូលគណនីរជ្ជទេយ្យការចំណូលរបស់ក្រសួងរ៉ែ និងថាមពល។ សម្រាប់ថ្នាក់រាជធានី ខេត្ត សម្បទានិកត្រូវបង់ថ្លៃឈ្នួលដីចូលគណនីរជ្ជទេយ្យការចំណូលរបស់មន្ទីររ៉ែ និងថាមពល រាជធានី ខេត្ត ដែលបានចេញអាជ្ញាបណ្ណនោះ។

ក្រសួងរ៉ែនិងថាមពល ត្រូវធ្វើរបាយការណ៍នៃការប្រមូលចំណូលថ្លៃឈ្នួលដី ប្រចាំត្រីមាស ឆមាស និងឆ្នាំ រួចផ្ញើជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ។

ប្រការ ៦.~

ក្នុងករណីអាជ្ញាបណ្ណត្រូវបានដកហូត ឬត្រូវបានបញ្ចប់ ថ្លៃឈ្នួលដីដែលបានបង់ត្រូវចាត់ទុកជាប្រយោជន៍ថវិការដ្ឋ។

ប្រការ៧.~

ក្នុងករណីសម្បទានិកខកខានមិនបានបង់ថ្លៃឈ្នួលដី ស្របតាមការកំណត់ក្នុងប្រកាសអន្តរក្រសួងនេះ សម្បទានិក ត្រូវទទួលរងនូវការពិន័យទៅតាមបទប្បញ្ញត្តិជាធរមាន។

ប្រការ ៨.~

សម្បទានិកដែលបានបង់ថ្លៃឈ្នួលដីរួចមុនប្រកាសនេះចូលជាធរមាន ត្រូវអនុវត្តការបង់ថ្លៃឈ្នួលដីចំពោះឆ្នាំដែលមិនទាន់បានបង់ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រកាសអន្តរក្រសួងនេះ ក្នុងរយៈពេលយ៉ាងយូរ៩០(កៅសិប)ថ្ងៃ ក្រោយប្រកាសនេះ ចូលជាធរមាន។

ប្រការ ៩.~

ប្រកាសអន្តរក្រសួងលេខ ១៧២ ឧរថ.អភរ.ប្រក និងលេខ ២៩១ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៩ ស្តីពីការកំណត់ថ្លៃចុះបញ្ជី ពាក្យសុំ (កម្រៃអាជ្ញាបណ្ណ) ការពន្យារបន្ត ការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានប៉ែ ឈ្នួលដីប្រចាំឆ្នាំនៃតំបន់សម្បទានសម្រាប់ការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានប៉ែ និងសួយសារធនធានប៉ែ ត្រូវទុកជានិរាករណ៍។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ១០.~

អង្គភាពពាក់ព័ន្ធក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងប៉ែ និងថាមពល ត្រូវទទួលបន្ទុក អនុវត្តតាមប្រកាសអន្តរក្រសួងនេះ ឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងរ៉ែ និងថាមពល

ចម្លងជូន÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១០ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ